00335319

លេខ/No: A252/2

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 01 / 06 / 2009
ម៉ោង (Time/Heure): 15 : 10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

## ការិយាល័យសហចៅក្រមស៊ើបអង្កេត

ថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០០៩

**ជូន៖** ក្រុមមេធាវីការពារក្តី អៀង សារី

**ពី៖** **ចៅក្រម យូ ប៊ុនឡេង**

**ចៅក្រម** Marcel Lemonde

សហចៅក្រមស៊ើបអង្កេត

**កម្មវត្ថុ៖** សំណើសុំផ្តល់ព័ត៌មានទាក់ទិននឹង លោក ស្ទីវហ្វិន ហេដឺ (Stephen Heder)

**យោង៖** 002/19-09-2007-ECCC-OCIJ/A252

តាមរយៈពាក្យសុំចុះថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០០៩ លោកស្នើសុំព័ត៌មានទាក់ទិននឹងលោក ស្ទីវហ្វិន ហេដឺ (Stephen Heder) *"ដើម្បីអាចវាយតំលៃពីសម្បទាសីលធម៌ និងវិជ្ជាជីវៈរបស់[គាត់] ក្នុងការបំពេញមុខងារជាអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត"*។ លោកយោងទៅដល់ *"ឯកសារមួយដែលទំនងជាមានលក្ខណៈត្រឹមត្រូវដែលបានផ្តល់ទៅឱ្យមេធាវីការពារក្តីដោយសម្ងាត់"* ដែលនៅក្នុងឯកសារនោះ លោក ហេដឺ បានលើកបង្ហាញពីគម្រោងសៀវភៅមួយ ដោយបានបញ្ជាក់ថា សៀវភៅនេះកើតចេញពីលទ្ធផលនៃការស្រាវជ្រាវរយៈពេល ៣០ ឆ្នាំ ផ្តោតទៅលើបក្សកុំម្មុយនីស្តកម្ពុជា (បកក) ក្នុងឋានៈដូចជា *"ភ្នាក់ងារកម្ម"*។ លោកបានសរសេរថា *"ដោយទទួលស្គាល់លោក ស្ទីវហ្វិន ហេដឺ បានបង្ហាញពីគម្រោងសៀវភៅនេះ ដូច្នេះមិនមានហេតុផលអ្វីដែលត្រូវសង្ស័យពីសំដីរបស់គាត់ឡើយ"*។ លោកធ្វើសេចក្តីសន្និដ្ឋានថា *"បើពិនិត្យមើលពីសញ្ញាតិរបស់គាត់*

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 01 / 06 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

*ទំនងអាចជឿបានថា គាត់បានធ្វើការឱ្យសេអ៊ីអា"*។ ហេតុដូច្នេះ នៅក្នុងឋានៈបែបនេះ គាត់បានទទួល និងបន្តទទួលការបញ្ជាពីផ្នែកចារកម្មបរទេស និង *"នាំឱ្យមានការសង្ស័យពីសម្បទារបស់គាត់ក្នុងបំពេញការងារដែលប្រគល់ឱ្យដោយឯករាជ្យ និងអនាគតិ"*។ អាស្រ័យហេតុនេះ លោកស្នើសុំយើងឱ្យផ្តល់ព័ត៌មានទាំងអស់ដែលយើងមាន អំពីមុខងារជាភ្នាក់ងារចារកម្មដែលលោក ហេដឺ បានបំពេញ និងធ្វើការបញ្ជាក់ថា តើ សាមីខ្លួនបានប្រាប់ឱ្យការិយាល័យសហព្រះរាជអាជ្ញា និងក្រោយមកការិយាល័យសហចៅក្រមស៊ើបអង្កេត ដឹងពីសកម្មភាពនេះដែរ ឬទេ *"ដើម្បីឱ្យ[មេធាវីការពារក្តី] អាចសម្រេចចិត្តថា ប្រសិនបើសម្រាប់ជាប្រយោជន៍ខាងយុត្តិធម៌ ធ្វើបណ្តឹងជំទាស់ជាផ្លូវការចំពោះរូបគាត់ ទៅអង្គបុរេជំនុំជម្រះ ដោយអនុវត្តតាមវិធាន ៣៤-៥ នៃវិធានផ្ទៃក្នុង"*។

យើង អាចត្រឹមតែរំលឹកជូនលោកជាថ្មីម្តងទៀតថា មិនមានមូលដ្ឋានគតិយុត្តសម្រាប់ការស្នើសុំបែបនេះទេ។

ជាក់ស្តែង ដូចយើងបានពន្យល់ជូនលោករួចហើយ[1] វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក មិនមានចែងពីលទ្ធភាពរបស់ភាគីមួយក្នុងធ្វើបណ្តឹងជំទាស់ចំពោះអ្នកស៊ើបអង្កេតទេ គឺអាចធ្វើបណ្តឹងជំទាស់តែចំពោះចៅក្រមប៉ុណ្ណោះ ដោយត្រូវធ្វើទៅតាមនីតិវិធីមួយច្បាស់លាស់ ដែលបែបបទនៃការធ្វើបណ្តឹងនេះ មានចែងនៅក្នុងវិធាន ៣៤។

ហេតុដូច្នេះ យើង មានសិទ្ធិមិនផ្តល់ចម្លើយតបនឹងសំណើសុំរបស់លោកបាន។ ប៉ុន្តែ ដើម្បីជៀសវាងកុំឱ្យមានការភាន់ច្រឡំនិងដើម្បីកាត់បន្ថយការបកស្រាយខុសឬដោយមិនត្រឹមត្រូវ យើង សូមបញ្ជាក់ប្រាប់លោកថា យើង មិនដឹងពីព័ត៌មានណាមួយ ឬមានឯកសារណាមួយដែលអាចឆ្លើយតបទៅនឹងការចោទប្រកាន់នានាដែលមាននៅក្នុងសំណើសុំរបស់លោកនោះទេ។

[1] សូមអានអនុស្សរណៈរបស់យើងចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០០៨ (A121/I)និងថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០០៨ (A121/III)